**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ៣២ សសរ

# សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតគណៈកម្មការ សម្រាប់ដោះស្រាយបញ្ហាកូដកម្ម បាតុកម្ម នៅតាមគ្រប់មុខសញ្ញា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាលកម្ពុជា

## សម្រេច

**ប្រការ ១ :** ត្រូវបានបង្កើតគណៈកម្មការសម្រាប់ដោះស្រាយកូដកម្ម បាតុកម្ម នៅតាមគ្រប់មុខសញ្ញា ដែលមានសមាសភាពដូចខាងក្រោមៈ

| | | | |
|---|---|---|---|
| ១- | ឯកឧត្តម អ៊ិត សំហេង | រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា | ប្រធាន |
| ២- | ឯកឧត្តម វង សូត | រដ្ឋមន្ត្រីក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ | អនុប្រធាន |
| ៣- | ឯកឧត្តម នេត សាវឿន | អគ្គស្នងការនគរបាលជាតិ | អនុប្រធាន |
| ៤- | ឯកឧត្តម កែប ជុតិមា | អភិបាលរាជធានីភ្នំពេញ | អនុប្រធាន |
| ៥- | ឯកឧត្តម សៅ សុខា | មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស | អនុប្រធាន |
| ៦- | ឯកឧត្តម ហ៊ីង ប៊ុនហៀង | នាយកងឯកកាល័យសម្តេចនាយករដ្ឋមន្ត្រី | អនុប្រធាន |
| ៧- | ឯកឧត្តម សុខ ចិន្តា | អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |
| ៨- | ឯកឧត្តម ប៊ុន សម | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | សមាជិក |
| ៩- | ឯកឧត្តម គីម ស៊ីថន | រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម | សមាជិក |

www.pheakdeylaw.com

| | | |
|---|---|---|
| ១០- ឯកឧត្តម ឆាន់ សាផាន | រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ | សមាជិក |
| ១១- ឯកឧត្តម សយ ស៊ីផុន | រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា | សមាជិក |
| ១២- ឯកឧត្តម ស្វាយ ស៊ីថា | រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ១៣- ឯកឧត្តម អ៊ិត ប្រាំង | រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល | សមាជិក |
| ១៤- ឯកឧត្តម ពិត ចំណាន | រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និង កីឡា | សមាជិក |
| ១៥- ឯកឧត្តម សូ ម៉ារ៉ា | រដ្ឋលេខាធិការក្រសួងទេសចរណ៍ | សមាជិក |
| ១៦- ឯកឧត្តម ឈន អឿម | រដ្ឋលេខាធិការក្រសួងធម្មការ និង សាសនា | សមាជិក |
| ១៧- ឯកឧត្តម អ៊ុំ មាន | រដ្ឋលេខាធិការក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| ១៨- ឯកឧត្តម មល់ អ៊ឿម | ទីប្រឹក្សាសម្តេចនាយករដ្ឋមន្ត្រី | សមាជិក |
| ១៩- ឯកឧត្តម យូ ស៊ុនឡុង | ទីប្រឹក្សាសម្តេចនាយករដ្ឋមន្ត្រី | សមាជិក |
| ២០- ឯកឧត្តម ឈុន ស៊ីរុន | អភិបាលខេត្តកណ្តាល | សមាជិក |
| ២១- ឯកឧត្តម ជុំ ហាក់ | មេបញ្ជាការរង កងទ័ពជើងគោកនៃអគ្គបញ្ជាការដ្ឋានកងយោធពលខេមរភូមិន្ទ | សមាជិក |
| ២២- ឯកឧត្តម ប៉ាល់ ចន្ទតារា | មេធាវីរាជរដ្ឋាភិបាល | សមាជិក |
| ២៣- ឯកឧត្តម អង់ គូនីប៉ា | សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ២៤- ឯកឧត្តម ឃួន រ៉ានីន | អនុរដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា | សមាជិក |
| ២៥- ឯកឧត្តម កែវ សុខសិទ្ធិនី | ទីប្រឹក្សាអមក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា | សមាជិក |
| ២៦- ឯកឧត្តម កើត ជឿន | ទីប្រឹក្សាអមក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា | សមាជិក |
| ២៧- ឯកឧត្តម សេង សក្តា | អគ្គនាយកក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| ២៨- ឯកឧត្តម ប្រាក់ ចាន់ធឿន | អគ្គាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា | សមាជិក |
| ២៩- ឯកឧត្តម ឡៅ សុគន្ធ | អគ្គនាយកកិច្ចការរដ្ឋបាលនិងហិរញ្ញវត្ថុ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | សមាជិក |
| ៣០- លោក ស៊ៀង សុខឃុនឌី | ប្រធាននាយកដ្ឋានហិរញ្ញវត្ថុ និងផ្គត់ផ្គង់ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | សមាជិក |
| ៣១- លោក សំហេង បូរស | ប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង និង ជានាយកខុទ្ទកាល័យរដ្ឋមន្ត្រី ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | សមាជិក |
| ៣២- អភិបាលខេត្តពាក់ព័ន្ធ | | សមាជិក |

**ប្រការ ២ :** គណៈកម្មការនេះមានភារកិច្ច :

- តាមដាន ប្រមូលព័ត៌មាន និងលើកវិធានការទប់ស្កាត់ ធ្វើអន្តរាគមន៍ដោះស្រាយតាមផ្លូវច្បាប់នូវរាល់បញ្ហាក្ងដកម្ម បាតុកម្ម ដែលកើតមានឡើងនៅតាមគ្រប់មុខសញ្ញា
- ណែនាំគោលការណ៍ វិធានការដោះស្រាយបាតុកម្ម ក្ងដកម្ម ដល់គ្រប់ក្រសួងស្ថាប័ន រាជធានី និង ខេត្ត
- ធ្វើរបាយការណ៍លើកសំណើអំពីវិធានការដោះស្រាយ និង លទ្ធផលការងារជូនរាជរដ្ឋាភិបាល ។

www.pheakdeylaw.com

**ប្រការ ៣** : គណៈកម្មការនេះត្រូវបង្កើតលេខាធិការដ្ឋានអចិន្ត្រៃយ៍មួយ ដែលមានទីតាំងនៅក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា ដើម្បីចាត់ចែងការងារប្រចាំថ្ងៃ។

**ប្រការ ៤** : សមាជិកនៃគណៈកម្មការទាំងអស់ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។ គណៈកម្មការនេះមានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា សម្រាប់សម្រួលការងារ។

**ប្រការ ៥** : ថវិកាចំណាយប្រើប្រាស់របស់គណៈកម្មការនេះត្រូវបញ្ចូលបន្ថែមក្នុងខ្ទង់ថវិការបស់ក្រសួង សង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា។

**ប្រការ ៦** : - នៅថ្នាក់រាជធានី ខេត្ត ត្រូវមានគណៈកម្មការដោះស្រាយកូដកម្ម បាតុកម្ម ប្រចាំរាជធានី ខេត្ត ដែលមានអភិបាលរាជធានី អភិបាលខេត្ត ជាប្រធាន អភិបាលរង ១រូប ជាអនុប្រធាន និងមានមន្ទីរអង្គភាពមានសមត្ថកិច្ចពាក់ព័ន្ធជាសមាជិក។

- នៅថ្នាក់ក្រុង ស្រុក ខណ្ឌ ត្រូវបង្កើតគណៈកម្មការដោះស្រាយកូដកម្ម បាតុកម្មតាមការចាំបាច់ ដោយមានអភិបាលក្រុង ស្រុក ខណ្ឌ ជាប្រធាន អភិបាលរងជាអនុប្រធាន និងមានការិយាល័យ អង្គភាពមានសមត្ថកិច្ចពាក់ព័ន្ធជាសមាជិក

- ការបង្កើតគណៈកម្មការដោះស្រាយកូដកម្ម បាតុកម្មរាជធានី ខេត្ត និង ក្រុង ស្រុក ខណ្ឌ ត្រូវកំណត់ដោយដីការបស់រាជធានី ខេត្ត។

**ប្រការ ៧** : សេចក្តីសម្រេចលេខ ៥២ សសរ ចុះថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ២០០៤ ស្តីពីការបង្កើតគណៈកម្មការសម្រាប់ដោះស្រាយកូដកម្ម បាតុកម្ម នៅតាមគ្រប់មុខសញ្ញា និង បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងសេចក្តីសម្រេចនេះត្រូវទុកជានិរាករណ៍ ។

**ប្រការ ៨** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា រដ្ឋមន្ត្រីក្រសួងទេសចរណ៍ អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ អភិបាលរាជធានី ខេត្ត និងសាមីខ្លួនដែលមានចែងក្នុងប្រការ ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ២០០៨

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ ៨
- ឯកសារ - កាលប្បវត្តិ

www.pheakdeylaw.com